ក

មាតិកា

I. ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៨-៤-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៤០៧/១៣៦ ស្តីពីការតម្លើងឋានៈទីប្រឹក្សាសម្តេចប្រធានរដ្ឋសភា ចំនួន ០២ រូប ៣១០៥

០៨-៤-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៤០៧/១៣៧ ស្តីពីការតែងតាំងឯកឧត្តម ចំនួន ០៣ រូប ជាទីប្រឹក្សាផ្ទាល់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាល ទី ៣ ៣១០៦

០៨-៤-២០០៧ -ព្រះរាជក្រឹត្យ នស/រកត/០៤០៧/១៣៥ ស្តីពីការប្រោសព្រះរាជទាននូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់សេនា ចំពោះ ឯកឧត្តម និងលោកជំទាវ ចំនួន ០៥ រូប ៣១០៧

II. រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

-អនុក្រឹត្យលេខ ៣១ អនក្រ.បក (មាននៅក្នុងរាជកិច្ចលេខ ២៨ ចុះថ្ងៃទី ១៥ ខែមេសា ២០០៧)

០៩-៤-២០០៧ -អនុក្រឹត្យលេខ ៣២ អនក្រ.បក ស្តីពីការផ្ទេរឡូតិ៍នេសាទលេខ ២ ខេត្តកំពង់ធំ និងចលនទ្រព្យ-អចលនទ្រព្យ ដែលបំរើឱ្យឡូតិ៍មករដ្ឋបាលជលផល ៣១០៨

០៦-៤-២០០៧ -អនុក្រឹត្យលេខ ២៩៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៣១១០

០៦-៤-២០០៧ -អនុក្រឹត្យលេខ ២៩៩ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ៣១១២

០៩-៤-២០០៧ -អនុក្រឹត្យលេខ ៣០០ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣១១៣

០៩-៤-២០០៧ -អនុក្រឹត្យលេខ ៣០១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣១១៤

១០-៤-២០០៧ -អនុក្រឹត្យលេខ ៣០២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣១១៥

១០-៤-២០០៧ -អនុក្រឹត្យលេខ ៣០៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣១១៦

១០-៤-២០០៧ -អនុក្រឹត្យលេខ ៣០៤ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៣១១៧

១០-៤-២០០៧ -អនុក្រឹត្យលេខ ៣០៥ អនក្រ.តត ស្តីពីការតែងតាំងមុខងារ នាយទាហាន ៣១១៨

១០-៤-២០០៧ -អនុក្រឹត្យលេខ ៣០៦ អនក្រ.តត ស្តីពីការផ្ទេរក្របខ័ណ្ឌកងពលតូចលេខ ៣១ របស់កងទ័ពជើងគោក មកដាក់ចំណុះកងទ័ពជើងទឹក ៣១១៩

១០-៤-២០០៧ -អនុក្រឹត្យលេខ ៣០៧ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយនគរបាលជាតិ ៣១២១

III_ការងារបណ្តាក្រសួង

១_ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

០៩-៤-២០០៧ -ប្រកាសលេខ ៣៨២ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ី.ជេ.យូ ភ្លើស ឧបភើរេសិន អ៊ិលធីឌី បង្កើតរោងចក្រ " កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះថា " ស៊ី.ជេ.យូ ភ្លើស ឧបភើរេសិន អ៊ិលធីឌី " ៣១២២

១២-៤-២០០៧ -ប្រកាសលេខ ៣៩០ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន វ៉ាយ & ភី ហ្គាមេន បង្កើតរោងចក្រ " កាត់ដេរសម្លៀកបំពាក់ " ដែលមានឈ្មោះ ថា " វ៉ាយ & ភី ហ្គាមេន " ៣១២៤

១២-៤-២០០៧ -ប្រកាសលេខ ៣៩១ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន វ៉ាស៊ី វ៉ាស៊ី ខេមបូ បង្កើតរោងចក្រ " បោកគក់ និងជ្រលក់ពណ៌ " ដែលមានឈ្មោះ ថា " វ៉ាស៊ី វ៉ាស៊ី ខេមបូ " ៣១២៦

២_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០៧២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស.ខេ.អេស.ខូ អិលធីឌី** ៣១២៨

០៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០៧៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សេង ហេង ៤១៣** ៣១៣០

០៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០៧៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ាង_ជីង ពាណិជ្ជ ខូ អិលធីឌី** ៣១៣២

០៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០៧៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឆៀ ឌី ត្រេឌីង** ៣១៣៤

០៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០៧៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេ.អូ.ត្រាវែល& ធួរ** ៣១៣៦

០៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០៧៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ពីជាណា ខូ អិលធីឌី** ៣១៣៨

គ

០៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០៨០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេល ស្គ័ត អ៊ិនធើណេសិនណល** ៣១៤០

០៥-០១-២០០៧ -លិខិតបញ្ជាក់លេខ ០០៨១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធី.អេស.អ** ៣១៤២

១០-០១-២០០៧ -លិខិតបញ្ជាក់លេខ ០១៣១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ញូ ខសម៉ូស ត្រេន ស្ព័រថេសិន** ៣១៤៤

ព្រះរាជក្រឹត្យ

នស/រកត/០៤០៧/ ១៣៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្មហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី៤ នីតិកាលទី៣ នាថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេច ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតម្លើងឋានៈទីប្រឹក្សាសម្តេចប្រធានរដ្ឋសភា :

១- ឯកឧត្តម **ចម ប៊ុរ៉យ** បច្ចុប្បន្នជាទីប្រឹក្សាផ្ទាល់សម្តេច ហេង សំរិន ប្រធានរដ្ឋសភា នីតិកាលទី៣ មានឋានៈ ស្មើរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

២- ឯកឧត្តម **ទុំ សំរិត** បច្ចុប្បន្នជាទីប្រឹក្សាផ្ទាល់សម្តេច ហេង សំរិន ប្រធានរដ្ឋសភា នីតិកាលទី៣ មានឋានៈ ស្មើរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២: បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនិងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : ប្រធានរដ្ឋសភា និង នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧.០៧០៤.១៤៦

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០០៧

លេខៈ ១៥៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិន្ដរត

ព្រះរាជក្រឹត្យ

នស/រកត/០៤០៧/១៣៧

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី៤ នីតិកាលទី៣ នាថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦ ស្ដីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់ សម្ដេច ហេង សំរិន ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំង :

១- ឯកឧត្ដម តែ ឡូរិន ជាទីប្រឹក្សាផ្ទាល់សម្ដេច ហេង សំរិន ប្រធានរដ្ឋសភា នីតិកាលទី៣ មានឋានៈ ស្មើរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

២- ឯកឧត្ដម សៀង ពិសិដ្ឋ ជាទីប្រឹក្សាផ្ទាល់សម្ដេច ហេង សំរិន ប្រធានរដ្ឋសភា នីតិកាលទី៣ មានឋានៈ ស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

៣- ឯកឧត្ដម មោក សុចរិន ជាទីប្រឹក្សាផ្ទាល់សម្ដេច ហេង សំរិន ប្រធានរដ្ឋសភា នីតិកាលទី៣ មានឋានៈ ស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : ប្រធានរដ្ឋសភា និង នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្ដម សីហមុនី

៣៤៧.០៧០៤.១៤៧

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ៨ ខែ មេសា ឆ្នាំ ២០០៧

លេខ: ១៥៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ.ថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៤០៧/១៣៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :

១-លោកជំទាវ នាង ចំន្ទថាណា

២-ឯកឧត្តម ស៊ុំ សន្និសិទ្ធ

៣-ឯកឧត្តម ថា យ៉ាង

៤-លោកជំទាវ តាល់ ណៃរ៉ុម

៥-ឯកឧត្តម ឆៀង សេង

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៧០៤.១៤៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០០៧

លេខ:១៥៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មេសា ឆ្នាំ២០០៧
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...៣៥...អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការផ្ទេរឡូត៍នេសាទលេខ ២ ខេត្តកំពង់ធំ និង ចលនទ្រព្យ អចលនទ្រព្យ ដែលចំណុះឱ្យឡូត៍មករដ្ឋបាលជលផល

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-បានឃើញអនុក្រឹត្យលេខ ៩៥ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០០២ ស្តីពីការបង្កើតក្រុមហ៊ុនផលុផល ជាសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ២០០៣ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអភិវឌ្ឍន៍វិនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសំភារៈកសិកម្ម និង ក្រុមហ៊ុនផលផល

-តាមសំណើរបស់ គណៈកម្មាធិការជាតិអភិវឌ្ឍន៍វិនិយោគរបស់រដ្ឋ លើសហគ្រាសចំការកៅស៊ូ ក្រុមហ៊ុនសំភារៈកសិកម្ម និង ក្រុមហ៊ុនផលផល

ស ម្រេ ច

មាត្រា ១ : -

ត្រូវបានផ្ទេរឡូត៍នេសាទលេខ ២ ខេត្តកំពង់ធំ រួមទាំងចលនទ្រព្យ-អចលនទ្រព្យ ដែលបំរើឱ្យឡូត៍នេសាទនេះ ដូចមានក្នុងឧបសម្ព័ន្ធជូនភ្ជាប់ ឱ្យមកស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋពាលផលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា ២ : -

រាល់ចំណូលដែលបានមកពីឡូត៍នេសាទលេខ ២ ខេត្តកំពង់ធំ ត្រូវបង់ចូលថវិការដ្ឋ ។

មាត្រា ៣ : -

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ :

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៧

ហ៊ុន សែន

កន្លែងទទួល

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចមានក្នុងមាត្រា ៤
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៩៨ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ
១៧

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន២១រូប ដែលមានស្នាដៃល្អក្នុងការចូលរួមកសាង និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ វិស័យគមនាគមន៍និងដឹកជញ្ជូន នៅខេត្តសៀមរាប ដូចមានរាយនាមខាងក្រោម :-

ក_មេដាយមាសការងារ :

១-លោក	ឃឿម មី	អនុប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូន ខេត្តសៀមរាប
២-លោក	គង់ ចាន់ត្រា	អនុប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូន ខេត្តសៀមរាប
៣-លោក	លឹម សុខន្ធី	អនុប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូន ខេត្តសៀមរាប
៤-លោក	កៅ ចេង	អនុប្រធានមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខេត្តសៀមរាប
៥-លោក	និត្យ សុផា	អនុប្រធាននាយកដ្ឋាន អាជ្ញាធរអប្សរា
៦-លោក	ពាំង ធីបុល	វិស្វករ នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តសៀមរាប
៧-លោក	ឌិត សេរីរត្ន័នា	វិស្វករ នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តសៀមរាប
៨-លោក	សាយ ពេជ្ររិទ្ធា	ប្រធានអង្គភាពបណ្តាញផ្លូវនៃមន្ទីរសាធារណការនិងដឹកជញ្ជូន ខេត្តសៀមរាប
៩-លោក	ម៉ៅ ធីសុខ	អភិបាលរងស្រុកពួក "អតីតៈប្រធានការិយាល័យ សាធារណការស្រុកពួក"
១០-លោក	ខៀវ ប្រុសេរី	ប្រធានការិ.រដ្ឋបាល-បុគ្គលិក នៃមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តសៀមរាប
១១-លោក	សួន រ៉ាម៉ូ	ប្រធានការិ.ផែនការ-គណនេយ្យ នៃមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តសៀមរាប

១២-លោក ឡឹក សុខាកុមារត្នី ប្រធានអង្គភាពស្ថាបនានិងគ្រឿងចក្រនៃមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តសៀមរាប
១៣-លោកស្រី យឿន សារ៉ាន់ អនុប្រធានការិ.រដ្ឋបាល បុគ្គលិក នៃមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តសៀមរាប
១៤-លោកស្រី យូ សុភាព បេឡាធិការការិ.ផែនការគណនេយ្យនៃមន្ទីរសាធារណការនិងដឹកជញ្ជូន ខេត្តសៀមរាប
១៥-លោក អ៊ឹង គឹមស៊ាន់ អនុប្រធានការិ.សាធារណការ នៃមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្តសៀមរាប
១៦-លោកស្រី ហ៊ឹម នារីរ័ត្ន គណនេយ្យករ នៃអាជ្ញាធរអប្សរា
១៧-លោក ឡៀម សីរ័ត្ន អនុប្រធានអង្គភាពបណ្ដុញលូនៃមន្ទីរសាធារណការនិងដឹកជញ្ជូន ខេត្តសៀមរាប
១៨-លោក អន គុណរ័ត្ន អនុប្រធានអង្គភាពស្ថាបនា និងគ្រឿងចក្រ នៃមន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តសៀមរាប

ខ-លេខាធិការដ្ឋាន :

១-កញ្ញា ឈឿន សុគន្ធារី មន្ត្រីការិ.ផែនការ-គណនេយ្យនៃមន្ទីរសាធារណការនិងដឹកជញ្ជូន ខេត្តសៀមរាប
២-លោក ម៉ែន សុវណ្ណី មន្ត្រីការិ.រដ្ឋបាល-បុគ្គលិក នៃមន្ទីរសាធារណការនិងដឹកជញ្ជូន ខេត្តសៀមរាប
៣-លោកស្រី មៀន សុខឿន មន្ត្រីការិ.ផែនការ-គណនេយ្យនៃមន្ទីរសាធារណការនិងដឹកជញ្ជូន ខេត្តសៀមរាប

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន និងអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែមេសា ឆ្នាំ ២០០៧
នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៥៧១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសុវត្ថារា
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយសុវត្ថារា** តាមលំដាប់ថ្នាក់ ជូនមន្ត្រីជាន់ខ្ពស់ ចំនួន០៥រូប ដែលមានគុណបំណាច់ និងស្នាដៃល្អ ក្នុងការចូលរួមកសាងនិងអភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធ វិស័យគមនាគមន៍ និងដឹកជញ្ជូន នៅខេត្តសៀមរាប ដូចមានរាយនាមខាងក្រោម :-

ក-មេដាយសុវត្ថារា ថ្នាក់ សេនា :

១-ឯកឧត្តម **ម៉ិន ឈាវិទ្ធ** អគ្គនាយក អាជ្ញាធរអប្សរា
២-ឯកឧត្តម **ស៊ឹម សុន** រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ " អតីតៈអភិបាលខេត្តសៀមរាប"
៣-ឯកឧត្តម **ចំរុង សុផល** អភិបាលរង ខេត្តសៀមរាប
៤-ឯកឧត្តម **សុខ ស៊ុនលីន** ទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា និងជាប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូន ខេត្តសៀមរាប

ខ-មេដាយសុវត្ថារា ថ្នាក់ អស្សឫទ្ធិ :

-ឯកឧត្តម **ស៊ឺន គង់** អគ្គនាយករង អាជ្ញាធរអប្សរា

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន និងអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។៚

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣០០ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនឯកឧត្តម **តេង សាវង្ស** អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលមានស្នាដៃល្អក្នុងការអភិវឌ្ឍន៍ព្រះពុទ្ធ-សាសនា ដោយបានបរិច្ចាគធនធាន ចូលរួមជួយកសាងសមិទ្ធផលនានាជាច្រើន នៅវត្តទួលអង្គក្រពើ សង្កាត់គោករកា ខណ្ឌដង្កោ រាជធានីភ្នំពេញ សរុបថវិកា ចំនួន ១២៨.១២៦ ដុល្លារ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា និងអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ... មេសា ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៣០១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្តល់មេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងជូនសប្បុរសជននៅប្រទេសម៉ាឡេស៊ី ចំនួន ០៥រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានា នៅវត្តទួលអង្គក្រពើ សង្កាត់គោករកា ខណ្ឌដង្កោ រាជធានីភ្នំពេញ ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

១-Ven Maha SONY	គង់នៅប្រទេសម៉ាឡេស៊ី	បច្ច័យចំនួន ១០.២៨៤ ដុល្លារ
២-Mr. M.THENAGARAN	សប្បុរសជននៅប្រទេសម៉ាឡេស៊ី	ថវិកាចំនួន ១១.៩៣៥ ដុល្លារ
៣-Mr.s SANDHI	សប្បុរសជននៅប្រទេសម៉ាឡេស៊ី	ថវិកាចំនួន ១០.២៥០ ដុល្លារ
៤-Mr. MICHAEL WONG KWEE KAI	សប្បុរសជននៅប្រទេសម៉ាឡេស៊ី	ថវិកាចំនួន ១០.១០០ ដុល្លារ
៥-Mr. TEO LIANG HEE	សប្បុរសជននៅប្រទេសម៉ាឡេស៊ី	ថវិកាចំនួន ១០.០០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា និងអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣០៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

១៧

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានចំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៧រូប ដែលបានបរិច្ចាគធនធានជួយកសាងសាលារៀន ព្រះវិហារ ផ្លូវលំ និងសមិទ្ធផលផ្សេងៗទៀត នៅវត្តអង្គប្រីយ ក្នុងឃុំសំរោង ស្រុកកំពត ខេត្តកំពត ដូចមានរាយនាមខាងក្រោម :-

ក_មេដាយមាសស្ថាបនាជាតិ :

១-ឧបាសិកា	**ឡៅ សាយអ៊ីម**	នៅប្រទេសអូស្ត្រាលី	ថវិកាចំនួន	១៩.០០០	ដុល្លារ
២-ឧបាសិកា	**លីវ នួច**	នៅប្រទេសអូស្ត្រាលី	ថវិកាចំនួន	១៦.០០០	ដុល្លារ
៣-លោក	**ឡៅ អាយនិច**	នៅប្រទេសអូស្ត្រាលី	ថវិកាចំនួន	១៥.០០០	ដុល្លារ
៤-លោក	**គីម សំអាត**	នៅខេត្តកណ្តាល	ថវិកាចំនួន	១០.៥០០	ដុល្លារ
៥-លោក	**តាំង យឹម**	នៅក្រុងភ្នំពេញ	ថវិកាចំនួន	១០.០០០	ដុល្លារ

ខ_មេដាយប្រាក់ស្ថាបនាជាតិ :

១-លោក	**ផាន់ ហ៊ុយគៀត**	នៅប្រទេសអូស្ត្រាលី	ថវិកាចំនួន	៧.០០០	ដុល្លារ
២-លោក	**ជួន ហាក់**	នៅប្រទេសអូស្ត្រាលី	ថវិកាចំនួន	៦.០០០	ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ [illegible] ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣០៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនបរទេស ចំនួន០៣រូប ដែលបានផ្តល់ថវិកាជួយកសាងសំណង់ផ្សេងៗ មានអគារស្នាក់នៅ គិលានដ្ឋាន របងឥដ្ឋ ។ល។ នៅបូរីកុមារកំព្រា ខេត្តកំពង់ធំ ដូចមានរាយនាមខាងក្រោម :-

១-លោកស្រី MANUELA PILIPP ភារធារីស្ថានទូតអាល្លឺម៉ង់ប្រចាំកម្ពុជា ថវិកាចំនួន ១០.០០០ ដុល្លារ

២-លោក HANS JOACHIM FOGL តំណាងសហគមន៍អាល្លឺម៉ង់នៅប្រទេសសឹង្ហបុរី ថវិកាចំនួន ២៦.៤០១ ដុល្លារ

៣-លោក GUY BECHET ប្រធានអង្គការប្រតិបត្តិការពិភពលោកថ្មី (OMN,Belgique) ថវិកាចំនួន ១៧.៣៦៨ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣០៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតម្លើងឋានន្តរស័ក្តិ នាយទាហាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

ស ម្រេ ច

មាត្រា១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ជូន

-លោកវរសេនីយ៍ទោ **គ្រាប់ ម៉ាញ** អត្តលេខ ០០៣៣១៩ នាយទាហានការពារផ្ទាល់

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង បណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣០៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងមុខងារ នាយទាហាន

៚៚*៚៚

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

ស ម្រេ ច

មាត្រា១ : ត្រូវបានតែងតាំងមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ជូន

-លោកវរសេនីយ៍ទោ **ខៀវ រំដោះ** អត្តលេខ ០១៨២៥៦ ជា នាយការិយាល័យសេនាធិការយោធា និងជាទីប្រឹក្សាយោធាអមស្ថានទូតកម្ពុជា ប្រចាំសហភាពមីយ៉ាន់ម៉ា ជំនួសលោកវរសេនីយ៍ឯក **ទី ទ៉ាន់ខឹម** ដែលត្រូវចប់អាណត្តិ ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង បណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣០ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរក្រុមខណ្ឌកងពលតូចលេខ ៣១ របស់កងទ័ពជើងគោក មកដាក់ចំណុះកងទ័ពជើងទឹក

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ពន្ធ័ចាត់តាំងអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្របក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលសមាសភាពក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

ស ម្រេ ច

មាត្រា១ :ត្រូវបានផ្ទេរក្រុមខណ្ឌកងពលតូចលេខ៣១ ចំណុះកងទ័ពជើងគោកមកដាក់ចំណុះបញ្ជាការដ្ឋានកងទ័ពជើងទឹកវិញ ដើម្បីមានកម្លាំងការពារកោះ និងឆ្នេរសមុទ្រ ។

មាត្រា២ : ចំពោះទីតាំងកងពលតូចលេខ៣១នេះ ត្រូវរក្សាទុកនៅដដែល ដើម្បីងាយស្រួលផ្លាស់ប្តូរវេនចុះបំពេញប្រតិបត្តិការតាមបណ្តាកោះ និងឆ្នេរទាំងនោះ ។

មាត្រា៣ : ពេលវេលាផ្ទេរប្រគល់នៅថ្ងៃទី ១០ ខែ **ឧសភា** ឆ្នាំ ២០០៧ ជាកំណត់ ទីកន្លែងប្រមូលផ្តុំធ្វើការផ្ទេរប្រគល់ នៅទីបញ្ជាការកងពលតូចលេខ ៣១ ។

មាត្រា៤ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣០៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ អគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១- លោកវរសេនីយ៍ទោ ម៉ិន សន អត្តលេខ ០៥៨២
២- លោកវរសេនីយ៍ទោ ម៉ៅ តារា អត្តលេខ ០៦៣៦
៣- លោកវរសេនីយ៍ទោ ប៊ុល សុគន្ធ អត្តលេខ ០៧៣៩
៤- លោកវរសេនីយ៍ទោ យឹម ធីរៈ អត្តលេខ ១៩១០
៥- លោកវរសេនីយ៍ទោ ម៉ារ សំបូរណ អត្តលេខ ០១៤៥១
៦- លោកវរសេនីយ៍ទោ ខិន សេង អត្តលេខ ០១៨០០
៧- លោកវរសេនីយ៍ទោ ឪ សុខា អត្តលេខ ៥១៣០០ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ០៤-៧ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៣៨២ ឧរម.កន.ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០៧

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៨៣៩/០៧ គ.វ.ក ចុះថ្ងៃទី១៣.០៣.២០០៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ស៊ី.ជេ.យូ ភ្លើស ខបភើរេសិន អ៊ិលធីឌី ចុះថ្ងៃទី០៧.០៣.២០០៧

សំរេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ស៊ី.ជេ.យូ ភ្លើស ខបភើរេសិន អ៊ិលធីឌី (C.J.U PLUS CORPORATION LTD.) តំណាងដោយ លោក JAI UKE CHA សញ្ជាតិកូរ៉េ អាយុ៤៩ឆ្នាំ កាន់លិខិតឆ្លងដែនលេខ SC1717017 ចុះថ្ងៃទី០១.០៤.២០០៥ បង្កើតរោងចក្រ "កាត់ដេរសម្លៀកបំពាក់" ដែលមានឈ្មោះថា "ស៊ី.ជេ.យូ ភ្លើស ខបភើរេសិន អ៊ិលធីឌី (C.J.U PLUS CORPORATION LTD.)" មានទីតាំងស្ថិតនៅ ភូមិព្រៃព្រីងជើង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។

ប្រការ២: មុនចាប់ផ្តើមដំណើរការរោងចក្រ ក្រុមហ៊ុនត្រូវជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឱ្យបានមុនរយៈពេល១៥ថ្ងៃ និងត្រូវផ្តល់ប្លង់ គ្រឿងចក្រ-គ្រឿងម៉ាស៊ីន មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្នុងរយៈពេល ២ខែ យ៉ាងយូរ ។

ប្រការ៣: រោងចក្រនេះ ត្រូវបានអនុញ្ញាតឱ្យ " កាត់ដេរសម្លៀកបំពាក់ " ហើយត្រូវផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្ម របស់រោងចក្រ តាមមាត្រា១៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ស៊ី.ជេ.យូ ភ្លើស ខបភើរេសិន អិលធីឌី ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀងៗខ្លួន ។

ប្រការ១០: ប្រកាសនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

អ៊ិត-ប្រាំង

ចម្លងជូន :

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាក្រុងភ្នំពេញ

" ដើម្បីជូនជ្រាប "

-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៣៩០ ឧរ៉ថ.ករ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ មេសា ឆ្នាំ ២០០៧

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស់/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៨៥៤/០៧ គ.វ.ក ចុះថ្ងៃទី១៥.០៣.២០០៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើរបស់ក្រុមហ៊ុន វ៉ាយ & ភី ហ្គាមេន ចុះថ្ងៃទី១៣.០២.២០០៧

សម្រេច

